**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៦ ស.ជ.ប

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក
## ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងតំណាងរដ្ឋាភិបាលបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិទាំងអស់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ជាទីរាប់អាន!
- បងប្អូនជនរួមជាតិជាទីមេត្រី !

ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីសោមនស្សរីករាយ និងកិត្តិយសដ៏ខ្ពង់ខ្ពស់ ចូលរួមអបអរសាទរជាមួយបងប្អូនជនរួមជាតិទាំងអស់ ក៏ដូចជារដ្ឋាភិបាល និងប្រជាជាតិជាង១០០ប្រទេសលើសកលលោក ក្នុងការប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ឆ្នាំ២០១៣។ ក្នុងឱកាសប្រារព្ធទិវាដ៏មានសារៈសំខាន់នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវមោទនភាពជាតិ ដែលប្រជាជនកម្ពុជាបានអនុវត្តកន្លងមកក្នុងបុព្វហេតុការពារថែរក្សា និងគាំពារបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា បរិស្ថានតំបន់ និងបរិស្ថានភពផែនដី ដើម្បីគាំពារគុណភាពបរិស្ថាន ក៏ដូចជាចូលរួមរក្សាលំនឹងបរិស្ថានក្នុងក្របខ័ណ្ឌសកលលោក សម្រាប់ទ្រទ្រង់ដល់ភាពសម្បូរសប្បាយរុងរឿងផ្នែកជីវភាព សម្ភារៈ និងជីវភាពស្មារតី និងគាំពារសុខុមាលភាពប្រជាជនកម្ពុជា និងមនុស្សជាតិគ្រប់ជាតិសាសន៍ លើភពផែនដីតែមួយដែលយើងកំពុងរស់នៅសព្វថ្ងៃនេះ។

ឆ្នាំនេះជាឆ្នាំទី១៩ ដែលប្រជាពលរដ្ឋកម្ពុជា រួមជាមួយប្រជាជាតិនានាលើសកលលោក បានចាត់តាំងប្រារព្ធទិវាបរិស្ថានពិភពលោក ហើយក៏ជាឆ្នាំទី១៧ ដែលប្រទេសកម្ពុជាយើងបានកំណត់យកថ្ងៃនេះ ជាថ្ងៃប្រារព្ធទិវាបរិស្ថានជាតិ។ នេះជាការប្រារព្ធស្របគ្នានឹងការប្រារព្ធទិវាបរិស្ថានពិភពលោក ក្រោមប្រធានបទមួយថ្មីទៀត ដែលបានលើកឡើងដោយអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) គឺ៖ «**គ្រូវពិចារណា - ពេល**

**បរិភោគ - ដើម្បីសន្សំសំចៃធនធាន** (THINK-EAT-SAVE) »។ ប្រធានបទនេះ បង្កប់នូវអត្ថន័យអប់រំ និងសកម្មភាពការពារបរិស្ថានយ៉ាងស៊ីជម្រៅ ព្រមទាំងជាការដាស់ស្មារតីមនុស្សជាតិគ្រប់រូប ឱ្យមានការភ្ញាក់រលឹកចូលរួមថែរក្សាបរិស្ថានរស់នៅរបស់យើង ប្រកបដោយភាពស្រស់បំព្រង និងភាពបៃតងជានិច្ច។ ប្រធានបទឆ្នាំនេះ ក៏ជាការដាស់តឿនដល់មនុស្សជាតិឱ្យចេះសន្សំសំចៃធនធានក្នុងការផលិតស្បៀងអាហារ មានជាអាទិ៍ ការសន្សំសំចៃវត្ថុធាតុដើមក្នុងធម្មជាតិ ការសន្សំសំចៃធនធានក្នុងខ្សែចង្វាក់ផលិតកម្មស្បៀង និងការសន្សំសំចៃថាមពល ព្រមទាំងឆ្លុះបញ្ចាំងឱ្យមានការគិតគូរដល់ការសន្សំសំចៃស្បៀង និងការសន្សំសំចៃភោគទ្រព្យជាស្បៀងអាហារផងដែរ។ ជាមួយគ្នានេះដែរ ប្រធានបទនៃទិវាបរិស្ថាន ៥ មិថុនានេះ ក៏ជំរុញឱ្យយើងទាំងអស់គ្នាធ្វើការពិចារណាប្រកបដោយវិចារណញ្ញាណ នៅពេលយើងបរិភោគ ដោយត្រូវយល់ឱ្យបានច្បាស់ថា បរិស្ថានធម្មជាតិជាប្រភពនៃស្បៀងអាហារដែលទ្រទ្រង់ការរស់នៅរបស់មនុស្សជាតិនៅទូទាំងពិភពលោក។ ដូច្នេះ យើងចាំបាច់ត្រូវតែចេះសន្សំសំចៃស្បៀងអាហាររបស់យើងគ្រប់ពេលវេលា។ ការបរិភោគខ្ជះខ្ជាយ ការបោះបង់ចោលភោគផលជាស្បៀងអាហារ និងសំណល់អាហារទៅក្នុងបរិស្ថាន ដែលជាហេតុនាំឱ្យកើតមានបាតុភាពបំពុលបរិស្ថានធ្ងន់ធ្ងរថែមមួយកម្រិតទៀតនោះ ក៏ជាបញ្ហាដែលយើងត្រូវពិចារណាផងដែរ។

**បងប្អូនជនរួមជាតិជាទីស្នេហា!**

បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជារដ្ឋាភិបាលនៃបណ្តាប្រទេសនានាលើពិភពលោក បាននិងកំពុងព្រួយបារម្ភ ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ក្នុងការដោះស្រាយបញ្ហាវិបត្តិបរិស្ថានធំៗ និងគ្រោះមហន្តរាយទាំងឡាយ ដែលបានកើតឡើងជារៀងរាល់ឆ្នាំ ដែលបង្កឡើងដោយបាតុភូតនៃការប្រែប្រួលអាកាសធាតុភពផែនដី។ ការប្រារព្ធទិវាបរិស្ថាន ៥ មិថុនាឆ្នាំនេះ ក៏ជាការអំពាវនាវ ជាការដាស់ស្មារតី និងការបណ្តុះមនសិការជាថ្មីទៀត ឱ្យមនុស្សជាតិគ្រប់ជាតិសាសន៍លើភពផែនដី ចូលរួមអនុវត្តសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងកិច្ចគាំពារគុណភាពបរិស្ថាន ដើម្បីជាប្រយោជន៍របស់មនុស្សជាតិគ្រប់រូប។

ពេលនេះ ភពផែនដីកំពុងផ្តល់ឱ្យយើងនូវធនធានស្បៀងអាហារគ្រប់បែបយ៉ាង ដើម្បីចិញ្ចឹមប្រជាជនប្រមាណ ៧ពាន់លាននាក់ ហើយនៅឆ្នាំ២០៥០ខាងមុខ អ្នកប្រាជ្ញប្រជាសាស្ត្រពឹងថា ចំនួនប្រជាជនពិភពលោកនឹងកើនឡើងដល់ ៩ពាន់លាននាក់។ អង្គការកសិកម្មនិងស្បៀងអាហារសហប្រជាជាតិ បានព្យាករណ៍ថាមួយភាគបីនៃផលិតកម្មស្បៀងអាហារពិភពលោក ត្រូវបានមនុស្សប្រើប្រាស់យ៉ាងខ្ជះខ្ជាយ និងស្បៀងអាហារខ្លះបានក្លាយជាសំណល់អាហារ ឬខាតបង់ដែលត្រូវបោះចោលទៅក្នុងបរិស្ថាន។ ការខ្ជះខ្ជាយសំណល់ចំណីអាហារ ជាការសបញ្ជាក់ពីការខាតបង់ដ៏ធំសម្បើមដែលធម្មជាតិបានផ្តល់ឱ្យ ហើយជាការបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន។

ដូច្នេះ ប្រជាជននៅទូទាំងពិភពលោកត្រូវតែពួតផ្តុំគ្នាជាកម្លាំងសាមគ្គីដ៏រឹងមាំ ដើម្បីចូលរួមក្នុងសកម្មភាពគាំពារសក្តានុពលស្បៀងអាហារដែលធម្មជាតិបានផ្តល់ឱ្យជាប្រយោជន៍សម្រាប់ចិញ្ចឹមមនុស្សឱ្យមានអាហារបរិភោគគ្រប់គ្រាន់ ដោយត្រូវផ្តើមចេញពីលំនៅដ្ឋានរបស់គ្រួសារនីមួយៗ និងបុគ្គលម្នាក់ៗ។ នេះគឺជាអំណាចក្នុងការសម្រេចចិត្តជាធ្លុងមួយ ដើម្បីរួមគ្នាកាត់បន្ថយសំណល់ចំណីអាហារ សន្សំសំចៃថវិកា និងកាត់បន្ថយផលប៉ះពាល់ឱ្យដល់កម្រិតអប្បបរមាទៅលើបរិស្ថានក្នុងខ្សែសង្វាក់ផលិតកម្មស្បៀង និងធានាខ្សែសង្វាក់ផលិតកម្មដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់។

នាពេលបច្ចុប្បន្ននេះ ផ្ទៃដីដែលប្រើប្រាស់សម្រាប់ផលិតស្បៀងអាហារលើពិភពលោក គឺមានប្រមាណ ២៥% នៃផ្ទៃដីដែលជាទីជម្រករបស់មនុស្សនិងសត្វ។ ក្នុងទំហំផ្ទៃដីប្រមាណ២៥%នេះ បានប្រើប្រាស់ទឹកសាប ប្រមាណ៧០% និងដីដែលបានមកពីការកាប់ព្រៃឈើប្រមាណ៨០% ហើយផ្ទៃដីដែលផលិតស្បៀងនោះ បាន បញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ៣០%។ ប្រការនេះគឺជាមូលហេតុដ៏ចម្បងមួយ ដែលធ្វើឱ្យបាត់បង់ធនធាន ជីវៈចម្រុះ និងការប្រែប្រួលការប្រើប្រាស់ដី។ ដូច្នេះ នៅពេលដែលយើងបរិភោគ យើងត្រូវគិតគូរដល់ការ សន្សំសំចៃស្បៀង ការសន្សំសំចៃធនធាន និងពិចារណាដល់កិច្ចគាំពារគុណភាពបរិស្ថាន។ ជាក់ស្តែង យើងអាច ជ្រើសរើសអាហារដែលមានផលប៉ះពាល់តិចលើបរិស្ថាន ពោលគឺជ្រើសរើសយកចំណីអាហារសរីរាង្គ ដែល មិនប្រើប្រាស់សារធាតុជាតិគីមីនៅក្នុងខ្សែសង្វាក់ផលិតកម្មអាហារ និងជ្រើសរើសទិញចំណីអាហារផលិតក្នុងស្រុក ដោយសារចំណីអាហារទាំងនោះ មិនត្រូវបានដឹកជញ្ជូនពីទីឆ្ងាយ ដើម្បីរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័ន ផ្ទះកញ្ចក់ផងដែរ។

**បងប្អូនជនរួមជាតិជាទីស្នេហា**!

ក្នុងការអនុវត្តគោលនយោបាយបរិស្ថាន រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់គោលការណ៍ «**ការអភិរក្ស ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍ ហើយការអភិវឌ្ឍត្រូវគាំពារដល់ការអភិរក្ស**»។ ផ្តើមចេញពី ការអនុវត្តគោលការណ៍នេះ នាខែមីនា ឆ្នាំ២០១៣កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសគោលនយោបាយ អភិវឌ្ឍន៍បៃតងជាតិយ៉ាងឱឡារិកនៅ*វិមានសន្តិភាព* ដែលជាសក្ខីភាពនៃការចូលរួមអនុវត្តស្មារតីនៃកិច្ចប្រជុំ របស់អង្គការសហប្រជាជាតិ *រីយ៉ូ+២០* ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពបរិស្ថាន ព្រមទាំងចូលរួមអនុវត្តស្មារ តីរបស់អង្គការអភិវឌ្ឍន៍បៃតងអន្តរជាតិយ៉ាងពិតប្រាកដ។ ការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍បៃតង គឺ ជាចលនានៃដំណើរអភិវឌ្ឍន៍មួយ ក្នុងការឈានទៅសម្រេចបានជោគជ័យលើការអភិវឌ្ឍប្រកបដោយចីរភាព និរន្តរភាពបរិស្ថាន និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងធានាបាននូវ ផលប្រយោជន៍ប្រកបដោយសមធម៌សង្គម ដោយឈរលើភាព**ឈ្នះ-ឈ្នះ**នៃសសរស្តម្ភទាំង៤គឺៈ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ ដែលជំរុញឱ្យកំណើនសេដ្ឋកិច្ចនៅកម្ពុជាធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ដែលបាននិងកំពុងកើតមាននៅក្នុងពិភពលោក។

ដូច្នេះ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតងរបស់រាជរដ្ឋាភិបាល គឺជាចក្ខុវិស័យឈានទៅសម្រេច បានការអភិវឌ្ឍប្រកបដោយចីរភាព សេដ្ឋកិច្ចបៃតង និងការពង្រឹងកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍបៃតង សកល រវាងប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីការពារភពផែនដីឱ្យ ស្ថិតស្ថេរគង់វង្ស តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច ការការពារបរិស្ថាន ការកាត់បន្ថយ សំណល់ ការសន្សំសំចៃធនធាន ការលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ជាការពិតណាស់ ធនធានធម្មជាតិដែលមានលើភពផែនដីមានកម្រិតកំណត់របស់វា ទាំងធនធានកកើត ឡើងវិញ និងធនធានមិនកកើតឡើងវិញ។ ប៉ុន្តែ តម្រូវការរបស់មនុស្សគ្មានព្រំដែនឡើយ។ ប្រការនេះបាន បង្កើតជាទំនាស់រវាងលទ្ធភាពផ្តល់របស់ធម្មជាតិដែលមានព្រំដែន និងសេចក្តីត្រូវការនិងការទាមទាររបស់មនុស្ស ដែលកើនឡើងឥតព្រំដែនកំណត់។ ដូច្នេះ យើងទាំងអស់គ្នាត្រូវធ្វើការរួមគ្នា ដើម្បីធានាឱ្យបាននូវសន្តិសុខស្បៀង និងសុវត្ថិភាពបរិស្ថាន សម្រាប់មនុស្សបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយៗទៀត។

**បងប្អូនជនរួមជាតិជាទីស្នេហា** !

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវការកោតសរសើរដោយស្មោះ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយជោគជ័យ គួរជាទីមោទនៈ ក្នុងកិច្ចការពារ ថែរក្សា និងគាំពារបរិស្ថាននៅកម្ពុជា។ ទន្ទឹមនឹងនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណចំពោះគ្រប់ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រះសង្ឃគ្រប់អង្គ ប្រជាពលរដ្ឋ និងសិស្ស-និស្សិតទាំងអស់ ដែលបានផ្តល់នូវកិច្ចសហប្រតិបត្តិការ និងចូលរួមយ៉ាងសកម្មភាពក្នុងការគាំពារបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមរាជរដ្ឋាភិបាល ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល សប្បុរសជនជាតិនិងអន្តរជាតិ ដែលបានចូលរួមជួយឧបត្ថម្ភថវិកា សម្ភារៈ ធនធានមនុស្ស និងបញ្ញាស្មារតី ដើម្បីជួយទ្រទ្រង់ដល់សកម្មភាពគាំពារបរិស្ថានកម្ពុជា ក៏ដូចជាបរិស្ថានតំបន់ និងបរិស្ថានពិភពលោក។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសឱ្យស្មារតីនៃការប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ឆ្នាំ២០១៣នេះ ក្លាយជាស្មារតីសាមគ្គី និងការអនុវត្តសកម្មភាពជាក់ស្តែងរួមរបស់មនុស្សជាតិ និងសូមឱ្យមនុស្សជាតិគ្រប់ជាតិសាសន៍មានមនសិការយល់ដឹងត្រឹមត្រូវ មានការតាំងចិត្តប្តូរផ្តាច់ និងចូលរួមឱ្យកាន់តែសកម្មថែមទៀត ក្នុងការធ្វើឱ្យភពផែនដីរក្សាបាននូវលំនឹងបរិស្ថាន និងបរិស្ថានមានភាពបៃតងជានិច្ច ព្រមទាំងចូលរួមបង្ការទប់ស្កាត់គ្រោះមហន្តរាយនានា ដែលកើតឡើងដោយសកម្មភាពមនុស្ស និងធម្មជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**